**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៣៤...សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

**សម្រេច**

**ប្រការ ១._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ | ប្រធាន |
| ២. ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣. ឯកឧត្តម **រ័ត្ន វីរៈ** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៤. ឯកឧត្តម **ឈន សុភាព** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |

| | | |
|---|---|---|
| ៥. ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៦. ឯកឧត្តម **វ៉ា ថន** | អភិបាលនៃគណៈអភិបាលខេត្តក្រចេះ | អនុប្រធាន |
| ៧. ឯកឧត្តម **ជា ម៉ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨. ឯកឧត្តម **កែន សត្ថា** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩. ឯកឧត្តម **កុល ធីរក្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០. ឯកឧត្តម **កែ គី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១១. ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២. ឯកឧត្តម **ហោច ចាន់ឆួន** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣. ឯកឧត្តម **ប្រាក់ សុខឃួរ** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៤. ឯកឧត្តម **ហាស់ សារ៉េត** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥. ឯកឧត្តម **ជា អូន** | រដ្ឋលេខាធិការប្រចាំការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៦. ឯកឧត្តម វេជ្ជបណ្ឌិត **សាន់ សាច់អ៊ី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៧. ឯកឧត្តម បណ្ឌិត **ប៉ាន សុបណ្ឌិត** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៨. ឯកឧត្តម **ថោង រដ្ឋសក្តិ** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៩. ឯកឧត្តម **ណោប សាមុត** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២១. ឯកឧត្តម **ម៉ូ រតនា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០. ឯកឧត្តម **ទួន ច័ន្ទរិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២២. ឯកឧត្តម **កើត ពុទ្ធថវី** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៣. ឯកឧត្តម **នុត អ៊ុនវ័ណ្ណរ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |

**ប្រការ ២.**

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តក្រចេះ ដើម្បីធានាបាននូវការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព
- សិក្សារៀបចំបង្កើតឲ្យមានផលិតផលទេសចរណ៍ថ្មីៗក្នុងខេត្តក្រចេះ សំដៅបង្កើតការទាក់ទាញភ្ញៀវទេសចរបន្ថែម និងពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរ
- ពិនិត្យសិក្សា រៀបចំបង្កើតឲ្យមានព្រឹត្តិការណ៍ទេសចរណ៍ សិល្បៈកម្សាន្តធំៗនៅពេលរាត្រីទាំងបុរាណ និងទំនើប ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដែលអាចសហការរៀបចំជាមួយវិស័យឯកជន នៅតាមទីតាំងគោលដៅទេសចរណ៍សំខាន់ៗ
- ជំរុញកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងក្របខ័ណ្ឌអភិវឌ្ឍទេសចរណ៍ តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា វៀតណាម និងឡាវ (CLV DTA)
- ជំរុញកិច្ចសហប្រតិបត្តិការ យុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី- ចៅប្រាយ៉ា- មេគង្គ (ACMECS)

- ជំរុញកិច្ចសហប្រតិបត្តិការទេសចរណ៍មហាអនុតំបន់មេគង្គ (GMS)
- ជំរុញកិច្ចសហប្រតិបត្តិការទេសចរណ៍ច្រករបៀងភាគខាងត្បូង (STC)
- ជំរុញការវិនិយោគទេសចរណ៍ និងសម្បទាទេសចរណ៍ដែលមានស្តង់ដាកម្រិតអន្តរជាតិ
- លើកកម្ពស់ការធ្វើដំណើរទេសចរណ៍តាមដងទន្លេមេគង្គ និងការភ្ជាប់ការធ្វើដំណើរទេសចរណ៍ ក្នុងតំបន់អភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា វៀតណាម និងឡាវ (CLV DTA)
- ពិនិត្យសិក្សា រៀបចំរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ដែលមានសក្តានុពលផ្សេងៗទៀត
- ជំរុញលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ដងទន្លេមេគង្គ និងការអភិរក្សធនធានបម្រើឲ្យវិស័យទេសចរណ៍
- អភិរក្ស និងលើកកម្ពស់ទេសចរណ៍បេតិកភណ្ឌ និងប្រវត្តិសាស្ត្រ
- ធ្វើរបាយការណ៍អំពីលទ្ធផល ឬរបាយការណ៍អំពីវឌ្ឍនភាពរបស់ខ្លួនជូនរាជរដ្ឋាភិបាលជ្រាប និងសុំការណែនាំយ៉ាងយូរបីខែម្តង
- បំពេញភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.**_

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥ មានលេខាធិការដ្ឋានមួយ ជាជំនួយការនៅក្រសួងទេសចរណ៍ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ថោង រដ្ឋសត្ថិ** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២. ឯកឧត្តម **ជុក ជំនោរ** | អគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣. លោកស្រី **ខាំ សុគន្ធា** | អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ | អនុប្រធាន |
| ៤. ឯកឧត្តម **អាំង សុវណ្ណរ័ត្ន** | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥. លោក **ជួប រតនា** | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍នៃក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៦. លោកជំទាវ **ម៉ូច ចរលក្ខណ៍** | នាយកវិទ្យាស្ថានជាតិទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិកា |
| ៧. ឯកឧត្តម **គីម សេរីរដ្ឋ** | អគ្គលេខាធិការរងនៃ គ.ជ.រ.ទ. និងជាប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅ និងម្ហូបអាហារទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ៨. ឯកឧត្តម **គង់ សុគន្ធរក្ស** | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានស្ថិតិទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ៩. លោក **ម៉ែន គារម្យ** | អគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍ | សមាជិក |
| ១០. លោក **សៀង នាគ** | អគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍ | សមាជិក |
| ១១. លោក **ស៊ូ គីមព្រឹទ្ធា** | ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងទេសចរណ៍ | សមាជិក |
| ១២. លោក **ចាន់ សុគន្ធី** | ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ | សមាជិក |

| | | |
|---|---|---|
| ១៣. លោក **នុត សុខា** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤. លោក **នួន សាវី** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៥. លោក **ឯក រដ្ឋា** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៦. លោក **ហាស់ ទិវឌ្ឍនា** | ប្រធានការិយាល័យវិនិយោគនៃទីចាត់ការផែនការ និងវិនិយោគសាលាខេត្តក្រចេះ | សមាជិក |
| ១៧. លោក **អ៊ូច លីណា** | ប្រធានការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៨. លោក **ម៉ូញ ឌី** | ប្រធានការិយាល័យអភិវឌ្ឍន៍ទេសចរណ៍តំបន់ឦសាន្ត នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៩. លោក **ឈីន សារិន** | ប្រធានការិយាល័យមហាអនុតំបន់ទន្លេមេគង្គ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២០. លោក **ផន សុភ័ក្ត្រ** | ប្រធានការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញនៃក្រសួងទេសចរណ៍ | សមាជិក |
| ២១. លោក **កែន ពេញ** | មន្ត្រីនាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ | សមាជិក |

**ប្រការ ៤._**

លេខាធិការដ្ឋាន គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍទេសចរណ៍ ខេត្តក្រចេះ ២០២៣-២០៣៥ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ប្រមូល ចងក្រង និងវិភាគទិន្នន័យនិងព័ត៌មាន ក្នុងការរៀបចំសេចក្តីព្រាងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ ខេត្តក្រចេះ ២០២៣-២០៣៥
- ធ្វើកិច្ចសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធនានាក្នុងការរៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់លើការងាររៀបចំសេចក្តីព្រាងឯកសារផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥
- រៀបចំកំណត់ហេតុកិច្ចប្រជុំ និងរបាយការណ៍វឌ្ឍនភាពការងាររបស់ក្រុមការងារ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

**ប្រការ ៥._**

អនុប្រធាន និងសមាជិក សមាជិកាគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារ និងកិច្ចប្រជុំជំនួស។

**ប្រការ ៦._**

គណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងវិស័យឯកជន ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៧._**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ ថវិកាក្រសួងសាមី និងថវិកាដែលបានពីប្រភពស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ ៨.**_

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៩.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ